# ស្ដីពីមេរោគថ្មី កូរូណា (COVID-19)

## ■ អ្វីទៅជាមេរោគកូរូណាថ្មី?

មេរោគថ្មីកូរូណា (**COVID-19**) ជាជំងឺផ្លូវដង្ហើម ដែលត្រូវបានរាយការណ៍ថាបានកើតឡើងនៅខេត្តហ៊ូប៉េ ប្រទេសចិននៅខែធ្នូ ឆ្នាំ២០១៩។ រោគសញ្ញានៃជំងឺនេះរួមមាន ការក្អក ក្ដៅខ្លួន និងមានរលាកសួត។ មេរោគនេះអាចឆ្លងតាមរយៈការក្អក ឬកណ្ដាស់ និងតាមការប៉ះពាល់គ្នា។

## ■ អ្នកដែលមានរោគសញ្ញាខាងក្រោម សូមទាក់ទង “មជ្ឈមណ្ឌលពិគ្រោះមេរោគកូរូណា”

- ផ្ដាសាយ និងមានកំដៅ លើសពី៣៧.៥ អង្សា ជាប់គ្នាលើសពី៤ថ្ងៃ (ឬលើសពី២ថ្ងៃ ចំពោះមនុស្សចាស់ និងអ្នកដែលមានជំងឺស្រាប់)
- មានអារម្មណ៍ហត់ខ្លាំង ឬពិបាកដកដង្ហើម

ប្រសិនបើមានការសង្ស័យថាមានឆ្លងមេរោគកូរូណា បន្ទាប់ពីការពិគ្រោះនៅមជ្ឈមណ្ឌលយើងនឹងណែនាំទៅ មន្ទីរពេទ្យជំនាញ។សូមទៅទទួលការពិនិត្យដោយពាក់ម៉ាស់ និងជៀសវាងការប្រើមធ្យោបាយធ្វើដំណើរសាធារណៈ។

### បញ្ជីរាយនាម មជ្ឈមណ្ឌលពិគ្រោះ មេរោគកូរូណា

https://www.mhlw.go.jp/stf/seisakunitsuite/bunya/kenkou_iryou/covid19-kikokusyasessyokusya.html

## ■ ការការពារការឆ្លង និងរីករាលដាលនៃមេរោគកូរូណាជាការចាំបាច់សម្រាប់ប្រជាជនគ្រប់គ្នា

ពេលមានរោគសញ្ញាក្ដៅខ្លួន ឬផ្ដាសាយ សូមសំរាកពីសាលា ឬក្រុមហ៊ុន

### វិធានការណ៍ការពារដោយខ្លួនឯង



- លាងដៃ និងខ្ពុលមាត់បន្ទាប់មកពីខាងក្រៅ
- លាងដៃនិងម្រាមដៃជាមួយអាកុល
- ជៀសវាងកន្លែងមានមនុស្សច្រើន
- ព្យាយាមឲ្យមាន ខ្យល់ចេញចូលក្នុងបន្ទប់
- បន្តជីវភាពរស់នៅតាមធម្មតា និងសម្រាកឲ្យបានគ្រប់គ្រាន់
- បរិភោគចំណីអាហារដែលមានគុណភាព និងផឹកទឹកឲ្យបានគ្រប់គ្រាន់



### វិធានការណ៍ការពារតាមរយៈ “ក្អកកណ្ដាស់”

- ពេលមានរោគសញ្ញាក្អក ឬកណ្ដាស់ សូមពាក់ម៉ាស់
- ពេលអត់ពាក់ម៉ាស់ សូមយកក្រដាសជូតមាត់ ឬដៃអាវទប់មាត់ និងច្រមុះ

### ព័ត៌មានផ្សេងៗ ទាក់ទងនឹងមេរោគថ្មី កូរូណា (ភាសាជប៉ុនងាយៗ អង់គ្លេស)

http://www.clair.or.jp/tabunka/portal/info/contents/114517.php

2020/2/28（一財）自治体国際化協会

# សូមនាំគ្នាលាងដៃ

## សូមលាងដៃនឹងសាប៊ូ តាមរបៀបខាងក្រោម

**ត្រៀមមុនពេលលាងដៃ**

◆មានកាត់ក្រចកឬនៅ?
◆មានដោះនាឡិកា និងចិញ្ចៀនឬនៅ?






**កន្លែងដែលងាយមានមេរោគ**

◆ចុងម្រាមដៃ
◆ចន្លោះម្រាមដៃ
◆ជុំវិញមេដៃ
◆កដៃ
◆បរិវេណជ្រួញដៃ

(1) លាងបាតដៃជាមួយពពុះសាប៊ូ



(2) ដុសខ្នងដៃទៅវិញទៅមក



(3) ដុសចុងម្រាម និងក្រចកដៃ



(4) លាងចន្លោះម្រាមដៃ



(5) លាង តាមរបៀបរមួលមេដៃដូចខាងក្រោម



(6) កុំភ្លេចលាងកដៃផងដែរ



លាងសាប៊ូចេញជាមួយនឹងទឹក រួចសំងួតដៃដោយប្រើកន្សែងជូតដៃ